មនុស្សដូចគេ បើមិនមែនជាមនុស្សអាក្រក់ជាអ្វីវិញ?

ជាច្រើនឆ្នាំមកនេះ ខ្ញុំបានព្យាយាមរកស៊ី ខំធ្វើគ្រប់វិធីឱ្យហាងនំរបស់ខ្ញុំឱ្យទទួលបានជោគជ័យ ក៏មិនមែនមានន័យថា ខ្ញុំលែងមានពេលវេលាសម្រាប់គិតអំពីអត្ថន័យជីវិត ការសប្បាយ ណាត់ជួបមនុស្សប្រុសទេ។

ខ្ញុំជានារីអាមេរិកម្នាក់ដែលធំដឹងក្ដីល្មមអាចគ្រប់គ្រងជីវិត និងមានតម្រូវការស្នេហាដូចគេឯងដូច្នេះ បុរសដែលខ្ញុំទាក់ទងតាមអ៊ីនធឺណិតម្នាក់ បង្ហាញខ្លួននៅមាត់ទ្វាររបស់ខ្ញុំ គេ..... មើលទៅកាន់តែសិចស៊ីជាងក្នុងអនឡាញទៀត។

ទីបំផុតខ្ញុំយល់ថា ជីវិតនេះ មានន័យយ៉ាងម៉េចក្នុងការស្អប់គេតែត្រូវការគេខ្វះមិនបានក្នុងពេលតែមួយ។

ខ្ញុំជាប់ចិត្តនឹង ជនជាតិអង់គ្លេសម្នាក់នេះ។

......

## ជំពូកទីមួយ

## រូបក្លែងក្លាយឬពិត

## អូយ! ហេតុអ្វី ដកភ្នែកមិនរួច?

រូបថតដែលគ្មានអាវរបស់មនុស្សនេះ ស្ទើរតែធ្វើឱ្យខ្ញុំចាក់សោទ្វារការិយាល័យ មុនម៉ោង ហើយចំណាយពេលសម្រាកអាហារថ្ងៃត្រង់យូរជាងរាល់ដង ឬអាចដល់ល្ងាច អាចទើសភ្លី.....ផងក៏ថាបាន។

គ្រប់គ្នាមានជីវិតឯកជន......វាជាផ្នែកមួយយ៉ាងពិសេសនៃការរស់នៅរបស់យើង។ គេជាបុរស.....សេវា...ពិសេសមកពីអង់គ្លេស ហើយមនុស្សក្នុងវេបសាយនេះ គ្មានទំនិញណាមួយ មើលភ្លាមបេះដូងញាប់ ដូចប្រុសម្នាក់នេះឡើយ។

ខ្ញុំហត់ណាស់ តែខ្ញុំមានលុយ ដូច្នេះ ខ្ញុំអាចមានលទ្ធភាពទិញសេចក្ដីសុខមួយនេះបាន ទោះណាមើលមកក្រោម តម្លៃគេ......ថ្លៃកប់អាកាស។

ដើមទ្រូងទទេរបស់គេ ដូចជាក្លូន? ឥតខ្ចោះ.....ចាប់ពីឆ្អឹងជំនីរបស់គេរហូតទៅដល់កន្លែង.....គាត់ ពោរពេញទៅដោយសាច់ដុំរាងអក្សរ V ដែលជំរុញឱ្យចិត្តនេះឆ្កួត ភ្នែកក្ដៅ មាត់ញញឹម ភ្លេចខ្លួនឯង។

ម្នាក់នេះ.....មួយលានភាគរយនៃប្រភេទបុរសក្នុងសុបិនរបស់ខ្ញុំ។

កាលិប ប្រ៊ីដអ៊ីស Caleb British !!!! ខ្ញុំខ្សឹបក្ដៅៗ អានឈ្មោះក្លែងក្លាយនៅខាងលើរូបបិសាចជញ្ជក់បេះដូងម្នាក់នេះសរសេរថា៖

«ខ្ញុំចូលចិត្តស្រីណាដែលមានភាព សិចស៊ី រាងស្រឡូន»

គេសរសេរបែបនេះដោយចំហ បន្ទាប់មក ពេលក្រឡេកមកផ្នែកមួយទៀតខាងស្ដាំដៃក្បែរបន្ទាត់កម្រងព័ត៌មាននោះ ជាប៊ូតុងពណ៌ក្រហមធំ Boldទុកថា«**ទាក់ទង**»

គ្រោះថ្នាក់ដឹង? តែចិត្តខ្ញុំកំពុងស្លុយ! ខ្ញុំខាំមាត់.....បើមិនគ្រោះថ្នាក់តិចៗ ម៉េចជា.....របស់ល្អ?

ម៉ែ! ខ្ញុំគិតថា....ខ្ញុំចង់ចុច.... ប៊ូតុងនោះ.....ចុចឥឡូវហើយ....

ខ្ញុំចង់និយាយថា.....យើងនឹងប៉ះគ្នាឬមិនប៉ះ មិនទាន់ដឹង ប៉ុន្តែអាចជាការសប្បាយក្នុងការផ្ញើសារទៅប្រុសស្អាតម្នាក់នេះ។ ចង់មើលថា.....ម៉េចដែរ?

...ការសម្រុកគិត ចង់ដឹង ចង់ផ្ទាញ់ និងសន្ទុះមានៈ លលាមដ៏គួរឱ្យអស់សំណើចមួយ កំពុងលលេងក្នុងបេះដូងខ្ញុំ។ អ្វីមួយប្រាប់ខ្ញុំថា....មិនអីទេ សម័យអីហើយ?

ខ្ញុំចុចប៊ូតុងទំនាក់ទំនង ខ្លឹប!!!....ចាំអង្កាល់? ហើយនៅរង់ចាំមើលទម្រង់ដែលលេចឡើងតបត។ ខ្ញុំខាំបបូរមាត់...ចិត្តហោះស្លុយបែកខ្ញែក....គេហទំព័រនេះ មើលម៉េចក៏ស្របច្បាប់ ដូចជាគ្មានផ្លូវស្មោគទេ?

«ប្រាប់មក បុរសប្រភេទណាដែលអ្នកចង់បាន?»

សំណួរលោតមកដំបូងគេនេះ បានធ្វើឱ្យខ្ញុំស្រាលជើង ហើយក្រហមមុខ។....ដូច្នេះ ខ្ញុំងើបមុខមកពិនិត្យទ្វារការិយាល័យជាលើកចុងក្រោយ ច្បាស់ថា គ្មានអ្នកណា......បន្ទាប់មកផ្អៀងអេក្រង់ ហើយចាប់ផ្ដើមបំពេញទម្រង់ចម្លើយ......ម្រាមនេះស្រើបនឹងឃ្លាសំនួរដ៏ពិសេស......បុកបេះដូងមែនតើ។

ខ្ញុំសរសេរវាទាំងអស់.....ចាំអង្កាល់? សរសេរ អ្វីគ្រប់យ៉ាងដែលខ្ញុំតែងតែខ្លាចក្នុងការចែករំលែកជាមួយពិភពលោក...ខ្ញុំកំពុងស្វែងរកបុរសម្នាក់ ដើម្បីបំពេញឱ្យខ្ញុំក្នុងរបៀបដែលគ្មាននរណាម្នាក់អាចយល់ដល់។

ខ្ញុំចង់.....ខ្ញុំសរសេរ។ ថ្ពាល់របស់ខ្ញុំឡើងក្រហមភ្លឺ សូម្បីតែវាយអក្សរទាំងនោះ ប៉ុន្តែខ្ញុំបន្តទៅមុខ.....

មានអារម្មណ៍ចម្លែកណាស់ដែលមកឃើញសំណេរទាំងនេះរបស់ខ្លួនឯង.....វាហូរចេញមកពីបេះដូង.....ដែលខ្ញុំចង់បាន....របៀបដែលខ្ញុំចង់បាន......គិតថា.....ខុសពីគេ.....ប៉ុន្តែនេះគ្រាន់តែជាការអនុវត្តសាកល្បងប៉ុណ្ណោះ ខ្ញុំប្រាប់ខ្លួនឯង....ខ្ញុំពិតជានឹងមិនជួបបុរសម្នាក់នេះទេ.....គ្រាន់តែសរសេរៗទៅមានទៅខាតអី?

ខ្ញុំចុចផ្ញើ និងបិទអេក្រង់ឱ្យលឿនតាមដែលអាចធ្វើទៅបាន។ បន្ទាប់មកខ្ញុំជូតចិញ្ចើម....ចូលក្នុង History សម្អាតអស់នូវរឿងទាំងនេះ ខ្ញុំមិនចង់ឱ្យកុំព្យូទ័រការងារ ឆ្លងមេរោគ ឬរក្សាអ្វីមួយឱ្យអ្នកណាអាចរកឃើញតម្រុយនៅពេលក្រោយ....ទេ។

ខ្ញុំបានរលាស់ខ្លួនចេញពីអារម្មណ៍ដែលបន្ទោសខ្លួនឯងថា ដោយសារភាពភ្លើតភ្លើនបន្តិច ខ្ញុំបានធ្វើការសម្រេចចិត្តដ៏ចម្លែកមួយ។

មកញុំាសាំងវិចចប់ហើយត្រលប់ចូលផ្ទះបាយវិញដោយមិនងាកក្រោយ។ គិតថាថ្ងៃនេះមានការបញ្ជាទិញច្រើន ចុងភៅញាប់ដៃ ហើយក្រុមDelivery កំពុងទន្ទឹងរង់ចាំ ខ្ញុំមកចង់បានម៉ោងលីបអីឯណាទៅកើត?

ហើយ.....អូខេ គេហទំព័រនេះប្រហែលជាបោកប្រាស់....ឬប្រសិនបើវាពិតៗ ពួកគេនឹងមើលប្រវត្តិរូបរបស់ខ្ញុំ ពីសារនោះ ហើយលុបចោល មិនខានព្រោះចម្លែកពេក ចរិតអាថ៌កំបាំង និងចំណង់ផ្តេសផ្តាសរបស់ខ្ញុំ។

ខ្ញុំបង្វែរអារម្មណ៍ខ្លួនឯងមកលើការងារវិញ។ យើងទទួលបានការបញ្ជាទិញច្រើនឡើងៗ ហើយងាកទៅគ្នាខ្ញុំធ្វើនំសេនវិចដោយយកចិត្តទុកដាក់ ហើយ......ខ្ញុំមានតែធ្វើជាចូលទៅជួយ ដើម្បីភ្លេចចោលពីរឿងរវើរវាយមុននេះ។

ប៉ុន្តែ បានប្រហែលកន្លះម៉ោង ទូរសព្ទរបស់ខ្ញុំក៏រោទ៍។ ខ្ញុំខិនមុខមកសម្លឹងក្នុងហោប៉ៅរបស់ខ្ញុំ ហើយសង្ស័យ។ អ្នកណាខលឬឆែត?

ខ្ញុំលាងដៃចេញ ដើម្បីមកចុចពិនិត្យមើល។ អ៊ីម៉ែលថ្មី!.....អូយ វរហើយ! ពីគេហទំព័រនោះ? ព្រះ!!...បេះដូងខ្ញុំលោតទើរលឺបលគាំងនៅ បំពង់ក....

ខ្ញុំចុចបើក.....លឺងបាន នាំខ្ញុំទៅកាន់កន្លែងមួយមានឈ្មោះថា .....Caleb British..... បេះដូងរបស់ខ្ញុំលោតញាប់ មានអារម្មណ៍ថា ដូចជាវាប៉ើងមកទើរជាប់នឹងករបស់ខ្ញុំ ។

ចំហាយនៃកំដៅអៀនខ្មាស សាយមកជុំជិតនៅពេលដែលខ្ញុំចុចបើកសារនោះ។

«Hey Hot Stuffed 😊 ខ្ញុំមានអ្វីដូចដែលនាងបានសរសេរ! សេចក្តីត្រូវការរបស់នាង!»

ថ្ពាល់របស់ខ្ញុំឡើងក្រហម ដង្ហើមដូចផ្សែងចំហុយ....។

ខ្ញុំនឹកដល់សំណេរខ្លួនឯង.....«ហើយខ្ញុំចង់ឱ្យ....ធ្វើឱ្យខ្ញុំមានអារម្មណ៍អស្ចារ្យ ឆ្អែតឆ្អន់តាមរបៀបដែលខ្ញុំមិនធ្លាប់.....មានពីមុនមក!»

ខ្ញុំលេបការថប់បារម្ភខ្លាំង។ មានអារម្មណ៍ចម្លែកណាស់ដែលឃើញសារត្រលប់ តិចអ្នកណាម្នាក់ស្គាល់ខ្ញុំច្បាស់ហើយស្តេម?

ព្រះ! ខ្ញុំបានសរសេរទាំងអស់ហើយ នូវអ្វីមួយដែលខ្ញុំចង់បាន យ៉ាងឆ្កួត គគ្រិច និងរបៀបដែលខ្ញុំស្រមៃ ហេតុអី?

«ខ្ញុំអាចបំពេញជូននាង ដូចការស្រមៃអស់ទាំងនោះស្រីស្អាត!»

សារតបមក ហើយបន្តមកទៀត «យប់នេះជាយប់ពិសេសក្នុងជីវិតអ្នក» ខ្ញុំភាំងពេលអានមិនមានវេលានឹងឆ្លើយតបផង « កាលវិភាគរបស់ខ្ញុំ ok សម្រាប់អ្នក! ឱ្យតែប្រាកដថា អ្នកអាច.....ទៅរួច!»

ខ្ញុំទម្លាក់ទូរសព្ទចោលហើយសម្លឹងជុំវិញ។

គ្រប់គ្នានៅធម្មតាជាមួយការងារប្រចាំថ្ងៃរបស់ពួកគេ លើកលែងតែខ្ញុំ.....មិនធម្មតាទេ។ ដៃខ្ញុំម្ខាងដែលទំនេរច្រត់ទៅក្រោយតុ។

សារលោតមកទៀត.....ខ្ញុំខំធ្វើជាក្លាហាន ឱនពិនិត្យសិន រួចទើបលើកមកអានបណ្ដើរៗ។

«Queen! ធានាថា ទីបំផុតនាងបានជួបដៃគូលើសង្វៀនស្លាប់រស់ហើយ!»

គេសរសេរមកយ៉ាងព្រហើន ហើយកខ្វក់តែមានឥទ្ធិពល។ ដៃខ្ញុំញ័របន្តិច តែកម្ដៅសាយភាយ។ គេនោះបានចុះហត្ថលេខាលើក្រដាសកិច្ច...S--នោះតែម្នាក់ឯង។ គ្មានឈ្មោះ គ្មានអ្វីផ្សេងទេ។ ប៉ុន្តែខ្ញុំមិនអាចបដិសេធបាន នូវសេចក្ដីប្រាថ្នាដ៏ជ្រាលជ្រៅដែលខ្ញុំកំពុងតែមានលើការកម្សាន្តឆ្គួតឡប់នេះដែរ។

នៅនឹងភ្នែកខ្ញុំ ខ្ញុំមិនមើលអ្វីឃើញទៀតទាំងអស់ ក្រៅតែពីបុរសសង្ហាអស្ចារ្យម្នាក់ ស្រមៃដូចគេកំពុងនិយាយជាមួយខ្ញុំ ម្នាក់នេះងើល ក្លាហានខ្លាំង មិនញញើតនឹងសំណើរបស់ខ្ញុំទេ ប៉ុន្តែក៏ហាក់ដូចជាគួរឱ្យសង្ស័យដែរ គេទៅរួចពិតមែន? ធ្វើឱ្យខ្ញុំទទួលអារម្មណ៍ថា បានទទួលឆ្អែត....គ្រប់គ្រាន់?

ឈប់សង្ស័យទៅ.....មានវិធីមួយគត់ ដើម្បីដឹងថា ពិតឬមិនពិត.....គឺស្វែងយល់!

ខ្ញុំក្រឡេកមួយជុំ ឱ្យមានសុវត្ថិភាព ហើយម្រាមដៃរបស់ខ្ញុំដាក់លើប៊ូតុងឆ្លើយតប។ មានកំណត់សម្គាល់តូចៗក្រោមនោះ ឱ្យខ្ញុំចុច....

8PM **ចុចកក់ទុក**

10PM **ចុចកក់ទុក**

ចំណុចមួយទៀតសរសេរថា **ទេ អរគុណ**។ បានន័យថា ខ្ញុំមិនយកសេវានេះទេ។ ខ្ញុំសម្លឹងមើលវាឡើងយូរ ជិតដល់មួយនាទី ហើយចាប់ផ្ដើមសើចនៅក្រោមដង្ហើមឆ្កួតឡប់ម្នាក់ឯងរបស់ខ្ញុំ។ បន្ទាប់មកខ្ញុំគ្រវីក្បាល ហើយដកដៃចេញមិនចុចអ្វីទាំងអស់ តើខ្ញុំកំពុងគិតអ្វី? នៅលើផែនដីនេះមានរឿងដែលខ្ញុំស្រមៃចង់បាន?

ប្រុងថាខ្ញុំឈានទៅការិយាល័យយកសោផ្ទះ ហើយចាកចេញទៅឡាន ស្រាប់តែ កូនចៅខ្ញុំម្នាក់គឺឡារ៉ា អ្នកគ្រប់គ្រងបញ្ជរលក់នៅខាងមុខ។ នាងដើរតម្រង់មកដោយរីករាយ មាត់ក៏ឡូឡាថា

«អស្ចារ្យ!» ខ្ញុំធ្វើមុខស្លេក ឡារ៉ាក៏ឈប់និយាយកណ្ដាលទី។ នៅពេលនោះ ដៃខ្ញុំបានជ្រុលទៅចុចជម្រើសឆ្លើយតបឱ្យបានលឿនតាមដែលអាចធ្វើទៅបាន ហើយព្យាយាមបិទវាមុនពេលឡារ៉ាមកឃើញសារ។

ជាអកុសល អេក្រង់ពិបាកដំណើរការ ហើយប៊ូតុងឆ្លើយតបដោយស្វ័យប្រវត្តិរបស់គេហទំព័រគឺមានភាពរញ៉េរញ៉ៃបន្តិច។ ខ្ញុំចុច Enter ដូចដែលខ្ញុំដឹងថា ខ្ញុំបានចុចលើជម្រើសត្រូវតែតាមពិតពេលនេះខ្ញុំមើលវាឡើងវិញ គឺវាចុចធ្វើទៅហើយ។ មាត់ខ្ញុំបើកចំហ! ហេតុអ្វី? ខ្ញុំបានជ្រើសរើសការកក់ម៉ោង 8PM ដោយចៃដន្យ ជំនួសឱ្យជម្រើស No Thanks។

ឡារ៉ាសម្លឹងខ្ញុំជំនួសសំណួរ។

«អត់ស្រួលខ្លួន ទៅផ្ទះមុនហើយ!»

«មុខនាងក្រហម! ត្រូវការទៅពេទ្យទេ?» ឡារ៉ាឆ្ងល់។

«មានអីឯណា» ខ្ញុំដកដង្ហើមធំហើយខំញញឹម។

«មែន?» ឡារ៉ាឱនមកពិនិត្យខ្ញុំពីលើដល់ក្រោម។

ឡារ៉ានាងមានការព្រួយបារម្ភ តែខាងនាងខ្ញុំឯណោះវិញ ខ្លាចការពិតក្នុងចិត្តលេចឡើងដោយស្វ័យប្រវត្តិមកក្រៅបានជារត់យ៉ាងរហ័សចេញមកចំណត។

What? «សូមអរគុណសម្រាប់ការកក់ម៉ោង!»

មើលហើយញីថ្ងាស។

យី!!!

«ការណាត់ជួបរបស់អ្នកត្រូវបានកំណត់នៅម៉ោង៨យប់ នៅអាសយដ្ឋាននៃប្រវត្តិរូបអនឡាញរបស់អ្នក ឬកន្លែងផ្សេង សូមបញ្ជាក់!»

ខ្ញុំចង់យំផង ចង់សើចផង។

ធ្វើម៉េច?

តើខ្ញុំលុបចោលវាដោយរបៀបណា?

ខ្ញុំឡើងអង្គុយក្នុងឡាន ហើយចុចលើអេក្រង់ដោយភ័យខ្លាច តែព្យាយាមស្វែងរកជម្រើសផ្សេងទៀត។ មិនមានជម្រើសក្នុងការឆ្លើយតបជាមួយសារសោះ «ឱ! ព្រះជាម្ចាស់អើយ ខ្ញុំមិនអាចឆ្លងកាត់រឿងនេះបានទេ ខ្ញុំដាក់លម្អិតច្រើនពេកហើយ រឿង......ស្អីៗអស់នោះ!»

ស្អីទៅ ឆ្អែតឆ្អន់រឿងលើគ្រែ? អូយ! ខ្ញុំត្រូវលុបចោលការណាត់នេះ!

ខ្ញុំឃើញឡារ៉ាឈរសំកាំងពីមុខហាងមើលមក នាងហាក់ឆ្ងល់ ខ្ញុំវិញខាំបបូរមាត់ចេញឡាន។

មកដល់ផ្ទះ បន្ទាប់ពីលុកលុយមួយសន្ទុះ ខ្ញុំរកឃើញប៊ូតុងទំនាក់ទំនងនៅផ្នែកខាងក្រោមនៃទំព័រនោះ ប៉ុន្តែកំណត់ថា អាចតែចន្លោះពីម៉ោង៩ព្រឹកដល់ម៉ោង៥ល្ងាច ហើយឥឡូវម៉ោងជិត៦ទៅហើយ។

ខ្ញុំព្យាយាមចុច ស្រាប់តែ «**យើងនឹងឆ្លើយតបក្នុងរវាង៤៨ទៅ៧២ម៉ោងសូមអធ្យាស្រ័យ**!»

«អ្ហ៎ា លេងសើចណាស់» ខ្ញុំស្បថម្ដងទៀតថាឈប់ធ្វើងងើលធុនហ្នឹងទៀត។

មុនពេលអាចដាក់ចិត្តថា ទៅងូតទឹក ខ្ញុំដកដង្ហើមធំ ហើយប្រាប់ខ្លួនឯងយ៉ាងសាមញ្ញថា បើប្រុសស្អាតមកមែន ចាំមើលតាមជាក់ស្ដែង តែបើយើងមិនពេញចិត្ត អាចឱ្យលុយគេ ត្រលប់ទៅវិញ។ អស់ខ្វល់!

តែ....អាចទេ យើងប្រហែលជាត្រូវបង់បន្ថែមនូវថ្លៃលុប.....ការងារ....ចោលឬអ្វី? ប៉ុន្តែ.....ហ៊ឹមនោះជាអ្វីធំដុំទៅ? សមនឹងការភ័យស្លន់ស្លោទេ?

អ៊ុំចឹង...

ខ្ញុំគ្រវីក្បាលស្អប់ខ្លួនឯងក្នុងកញ្ចក់! ទេ! ខ្ញុំមិនត្រៀមស្លៀកពាក់អ្វីពិសេស ស្ប៉ាខ្លួន ដើម្បីជួបបុរសម្នាក់នេះទេ ខ្ញុំនឹងបើកទ្វារហើយប្រាប់គេថា ជាការយល់ច្រឡំដ៏ធំមួយ តែមិនត្រូវការគេទេ រួចហើយចូលគេងលឿនជាងរាល់ដង។

តែ....

ច្បាស់ណាស់ថា ខ្ញុំគេងមិនលក់។

សង្ឃឹមថាបន្ទាប់ពីងូតទឹកយូរ និងមានពេលពិចារណាលើជម្រើសជីវិតរបស់ខ្ញុំ ខ្ញុំនឹងធ្វើឱ្យប្រសើរឡើងនៅថ្ងៃស្អែក ឈប់គិត ឬលេងរបៀបនេះទៀត។

បានសន្យាជាមួយខ្លួនខ្ញុំហើយ ក៏បានទៅងូតទឹក និងកក់សក់ហើយក្រោយផ្លុំស្ងួត ខ្ញុំបែរជាបន្តថ្ងៃម៉ូតសក់ដូចប្រុងចេញក្រៅ។ ស៊ីនេះ លាបម្សៅខ្លះទៀត? មានន័យថាម៉េច? ហើយ ម្រាមកំពុងប៉ះម៉ាស្ការ៉ាទៀត?

សាក្ខរៗ គ្រាន់តែ.....ក្នុងករណី.....

គ្រាន់តែគិត ធ្វើឱ្យខ្ញុំមានអារម្មណ៍ថា មិនសូវភ័យបន្តិចទេ ដែលដឹងថាខ្ញុំមើលទៅសមរម្យ។

ខ្ញុំដើរទៅបង្អួចឆែកមើលទៅក្រៅ។ មានអារម្មណ៍ថា ធ្វើអ៊ីចឹងជាលើកទីដប់ហើយ ដែលស្ទុះមកពិនិត្យមើលផ្លូវខាងក្រៅផ្ទះ ក្នុងឫកពាឆ្ងក់ៗ។

មិនទាន់មានសញ្ញារថយន្តបញ្ឈប់ក្បែរហ្នឹងទេ។

ខ្ញុំអង្គុយចុះ លើសាឡុងទន់ ហើយបង្ខំខ្លួនឯងឱ្យសមាធិ កុំរត់ទៅវែកវាំងននទៀត។

គេនឹងមក ពេលដែលត្រូវមក ឈប់អន្ទះសាទៅ....ឬប្រហែលជា គេនឹងមិនមក.....មនុស្សសង្ហាដូចគេ។ ប្រហែលជា.....ការយល់ច្រឡំដ៏ធំមួយនៅខាងគេដូចគ្នា។

ខ្ញុំឃើញខ្លួនឯងអធិដ្ឋានថា គេនឹងមិនបង្ហាញវត្តមាន បន្ទាប់មកខ្ញុំអាចដកថយពីជាន់នេះឡើងទៅលើ ព្យាបាលខ្លួនឯង ឱ្យរីករាយជាមួយភាពឯកោនេះល្អជាង មានសុវត្ថិភាពជាង....អរគុណច្រើន អរគុណច្រើនព្រះជាម្ចាស់ ដែលឱ្យមកខ្ញុំនូវសេរីភាពនេះ.....ហើយចូលគេងមុនម៉ោង។

យ៉ាងហោចណាស់.....ខ្ញុំនឹងមានចំណីអារម្មណ៍ល្អមួយ សម្រាប់ការស្រមើស្រមៃរបស់ខ្ញុំខ្លួនឯងនៅយប់នេះ។ ខ្ញុំសង្ស័យថា រូបថតនោះបានកែពង្រួមពោះធំកំពីងពិតរបស់គេផងក៏មិនដឹង គ្មានផ្លូវណាដែលលោកនេះ មានបុរសម្នាក់ដែលមានរាងកាយល្អឥតខ្ចោះហើយមកធ្វើសេវាអ៊ីចឹងៗនោះឡើយ។ នេះមិននិយាយពីមុខដូចតួរបស់គេ ឆ្អឹងថ្ពាល់ណែន ពុកចង្កាដ៏កាចៗចាយរាង ច្រមុះតូចហើយ.... របៀបដែលគេសម្លឹងមើលមកអេក្រង់ មានអារម្មណ៍ថា អាចថ្លក់គ្នាកាត់ពីលើរយៈចម្ងាយមកតាមកុំព្យូទ័រចូលក្នុងបេះដូងខ្ញុំ។

តើរូបរាងនេះ ភ្នែកសម្លឹងបែបនេះ មានអានុភាពខ្លាំងប៉ុនណាទៀតបើមកឈរក្បែរគ្នាក្នុងជីវិតពិត?

មិនអាចជួយខ្លួនឯងបានក្នុងការបំភ្លេចសោះ ខ្ញុំស្រាប់តែស្រមៃឃើញគេមកនៅក្នុងបន្ទប់នេះជាមួយខ្ញុំ។ ខ្ញុំចាប់ផ្ដើមស្រមៃថា តើគេនឹងបំពេញការសន្យាបានយ៉ាងជាក់លាក់មែន? ពាក្យថា«ខ្ញុំអាចបំពេញជូននាង ដូចការស្រមៃអស់ទាំងនោះស្រីស្អាត!»។

ខ្ញុំស្រមៃថា គេនឹងមកទ្រាបពីលើខ្ញុំនៅលើសាឡុងក្នុងបន្ទប់ទទួលភ្ញៀវនេះ ហើយខ្ទាស់ដៃខ្ញុំទៅនឹងខ្នើយ ខណៈពេលដែលដោះខ្សែក្រវាត់របស់ខ្ញុំ រត់ដៃមួយតាមថ្ពេរនៃខោរបស់ខ្ញុំ។ ស្រមៃថា គេមានម្រាមដៃដ៏រឹងមាំ ក្រាស់ ល្មមអាចធ្វើឱ្យខ្ញុំ.....

----------------

កណ្ដឹងទ្វារ.... បន្លឺឡើង។

ខ្ញុំដកដង្ហើមធំ....ហើយលោតចេញពីសាឡុង។

ចប់ហើយ! ខោរបស់ខ្ញុំមានអារម្មណ៍ថាសើម?

ខ្ញុំទុកឱ្យការស្រមើស្រមៃរបស់ខ្ញុំទៅឆ្ងាយយ៉ាងនេះ? សមាធិ ហ្សាមីន? ខ្ញុំនឹងមិនធ្វើបាបបុរសនេះជាមួយអារម្មណ៍តណ្ហាឆ្កួតៗហ្នឹងទេ។

ខ្ញុំមកនេះ ពេលនេះ គឺដើម្បីពន្យល់ពីការចុចខុស ហើយសុំឱ្យគេទៅធ្វើការកន្លែងផ្សេង។

ខ្ញុំឆ្លងកាត់បន្ទប់ទទួលភ្ញៀវ ដោយដកដង្ហើមធំ ហើយបើកទ្វារ។

បន្ទាប់មក ខ្ញុំក៏បាត់ខ្យល់ដង្ហើមនោះម្ដងទៀត។

បុរសដែលឈរនៅមាត់ទ្វារផ្ទះខ្ញុំ ហាក់ដូចជាទើបតែដើរចេញពីសុបិនសើមរបស់ស្រ្តីគ្រប់រូប។ គេស្លៀកពាក់ធម្មតា ក្នុងឈុតអាវយឺតដែលបង្ហាញពីដុំពកប៉ោង ដើមទ្រូងដ៏រឹងមាំ និងសូម្បីតែក្បាលពោះរាបស្មើ ខ្ញុំអាចរាប់រនាំង ទាំង៦តាមចង្អូរក្រណាត់។

ស្មានថារូបថតនោះត្រូវបានគេយកទៅប្រើ Photoshop ទេតើ។

ដូចដែលបានរំពឹងទុក ភ្នែកពណ៌ប្រផេះដែលទម្លុះមកនេះ រឹតតែខ្លាំងនៅទីនេះ ជាងកាលក្នុងអេក្រង់។ គេញញឹម.....ព្រះ!

ស្នាមញញឹមពាក់កណ្ដាលស្ទើរៗ ដែលធ្វើអោយបេះដូងខ្ញុំក្ដុកក្ដួលក្នុងទ្រូង ហើយក្បាលពោះរបស់ខ្ញុំក៏តឹងណែនដោយការ......។ គេមើលទៅត្រៀមខ្លួន ដើម្បីស៊ីខ្ញុំទាំងរស់ ហើយខ្ញុំ...ចង់ឱ្យគេធីឱ្យអស់ទៅ តាមចិត្ត....។